ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
០១១ ឧស៥.ររជរ.សណន.

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ តុលា ... ៥

# សេចក្តីណែនាំ
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងក្នុងទិសដៅដើម្បីគ្រប់គ្រងការធ្វើអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ សំដៅធានាដល់ការប្រមូលចំណូលរដ្ឋឱ្យបានជាអតិបរិមា និងធានានូវភាពត្រឹមត្រូវ សមស្របក្នុងការធ្វើអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សូមធ្វើការកំណត់គោលការណ៍គ្រប់គ្រងការធ្វើអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ដូចខាងក្រោម :

### I – ការគ្រប់គ្រងផលត្បូង (ត្បូងនៅមិនទាន់កែច្នៃ) ដែលជីកយកបាន

- ត្បូងថ្មដែលជីកយកបានត្រូវរក្សាទុកក្នុងប្រអប់ត្បូងសុវត្ថិភាពដែលត្រូវគ្រប់គ្រងដោយក្រុមការងារចំរុះមួយដែលរួមមាន :
  - តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជាប្រធាន
  - តំណាងសម្បទានិកកាន់អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ សមាជិក
  - តំណាងក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
  - តំណាងអាជ្ញាធរដែនដី ខេត្ត-ក្រុង សាម៉ី សមាជិក
  - តំណាងមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត-ក្រុង សាម៉ី សមាជិក
- សមាជិកទាំងអស់ក្នុងក្រុមការងារនេះត្រូវបិទភ្ជិតប្រអប់ត្បូងសុវត្ថិភាពដោយមានចុះហត្ថលេខាលើផ្ទុំបេ ( SEAL ) ក្រោយពេលបើកប្រអប់ម្តងៗ ។ សោរសុវត្ថិភាព សំរាប់ចាក់ប្រអប់ត្បូងសុវត្ថិភាព

មានចំនួន ២ (ពីរ) ដែលមួយត្រូវកាន់កាប់ដោយតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង មួយទៀតត្រូវកាន់ដោយតំណាងអ្នកកាន់អាជ្ញាប័ណ្ណ ។

- ការបើកប្រអប់ត្បូងសុវត្ថិភាព ត្រូវបើកនៅចំពោះមុខសមាជិកក្រុមការងារទាំងអស់ដែលក្រសួងបាន ចាត់ឱ្យទៅបំពេញការងារត្រួតពិនិត្យប្រអប់ត្បូងសុវត្ថិភាពនេះ ។
- ទីកន្លែងបើកប្រអប់ត្បូងសុវត្ថិភាពត្រូវធ្វើនៅកន្លែងណាមួយដែលសមាជិកក្រុមការងារទាំងអស់ យល់ព្រម ហើយត្រូវតែឋិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលធានាសុវត្ថិភាពទាំងក្នុងពេលដឹកជញ្ជូន និងក្នុង ពេលបើកប្រអប់សុវត្ថិភាព។ ក្នុងករណីល័ក្ខខ័ណ្ឌសុវត្ថិភាពពុំត្រូវបានធានាទេនោះ សមាជិក ក្រុមការងារ ទាំងអស់អាចកំណត់ទីកន្លែងបើកប្រអប់សុវត្ថិភាពនៅកន្លែងផ្សេងទៀតដោយ មាន ការយល់ព្រមពី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

## II - ការកំណត់តម្លៃផលត្បូងដែលជីកយកបាន

ការកំណត់តម្លៃផលត្បូងត្រូវធ្វើឡើង និងយល់ព្រមដោយភាគីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងអ្នក កាន់អាជ្ញាប័ណ្ណដោយដោយផ្អែកតាមតម្លៃនៅទីផ្សារអន្តរជាតិ (ឬផ្អែកតាមតម្លៃទីផ្សារត្បូងនៅទីក្រុងបាងកក)។ ក្នុងករណីការកំណត់តម្លៃផលត្បូងរបស់ក្រសួងខ្ពស់ជាងតម្លៃកំណត់របស់អ្នកកាន់អាជ្ញាប័ណ្ណ ហើយអ្នកកាន់អាជ្ញាប័ណ្ណ មិនព្រមទិញនោះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងធ្វើការដេញថ្លៃផលត្បូងទាំងនោះជាសាធារណៈ ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃយ៉ាងយូរ ក្រោយពីបានធ្វើការវាយតម្លៃ។ តម្លៃមូលដ្ឋានដែលដាក់សម្រាប់ ដេញថ្លៃឡើង ត្រូវខ្ពស់ជាងតម្លៃដែលអ្នកកាន់អាជ្ញាប័ណ្ណបានស្នើ និងទាបជាងតម្លៃដែលក្រសួងបានដាក់ក្នុងពេល វាយតម្លៃ។

## III- ភាតព្វកិច្ចហិរញ្ញវត្ថុ

អនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អ្នកកាន់អាជ្ញាប័ណ្ណអាជីវកម្មរ៉ែ ត្បូងថ្មមានតម្លៃ មានកាតព្វកិច្ចបង់ជូនរដ្ឋនូវឈ្នួលផ្ទៃដីសម្បទានប្រចាំឆ្នាំ សួយសារលើផលត្បូងដែលជីកយកបាន ឈ្នួលអាជីវកម្មប្រចាំខែ និង ពន្ធអាករផ្សេងៗទៀត ដោយអនុវត្តទៅតាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងច្បាប់ បទបញ្ញត្តិពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាន (ខ្លឹមសារលំអិតមានចែងនៅក្នុងកិច្ចព្រមព្រៀង)។

## IV- **ការស្តារបរិស្ថានតំបន់ឡើងវិញ**

អ្នកកាន់អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ត្រូវធ្វើការស្តារបរិស្ថានឡើងវិញទៅតាមផែនការស្តារបរិស្ថានឡើងវិញ ដែលបានយល់ព្រមដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។ ការតំកល់ប្រាក់សំរាប់ស្តារបរិស្ថានឡើងវិញ ត្រូវអនុវត្តទៅតាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ខ្លឹមសារលំអិតមានចែងនៅក្នុងកិច្ចព្រមព្រៀង) ។

## V- **ការលក់ ឬ ការនាំចេញផលត្បូង**

អ្នកចុះកិច្ចសន្យា ត្រូវសុំអាជ្ញាប័ណ្ណផ្សេងទៀតទៅស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីលក់ ឬនាំចេញផលត្បូងទាំងអស់ ឬមួយផ្នែក ដែលជីកយកបានមកពីតំបន់កិច្ចសន្យា ដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (ខ្លឹមសារលំអិតមានចែងនៅក្នុងកិច្ចព្រមព្រៀង) ។

អ្នកកាន់អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ត្រូវអនុវត្តតាមសេចក្តីណែនាំនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

ស៊ុយ សែម